**ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា**

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី០៧ ខែមិនា ឆ្នាំ២០១៤

## ជប៉ុនផ្តល់ ១៤៤,៧៥០ ដុល្លារអាមេរិកដើម្បីកែលម្អការអប់រំនៅកម្រិតបឋមសិក្សា និងអនុវិទ្យាល័យនៅតំបន់ជនបទនៃកម្ពុជា



ក្រោមគ្រោងការណ៍នៃជំនួយឥតសំណងសម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន រដ្ឋាភិបាលជប៉ុន បានផ្តល់ទឹកប្រាក់ សរុប ចំនួន ១៤៤,៧៥០ ដុល្លាអាមេរិកដល់សមាគមជំនួយសាលារៀននៅកម្ពុជា (ASAC) សម្រាប់គម្រោងសាងសង់ និង ជួសជុល អនុវិទ្យាល័យ និង សាលាបឋមសិក្សាក្នុងខេត្តកំពត។ កិច្ចសន្យាផ្តល់ជំនួយ ត្រូវបានចុះហត្ថលេខា ថ្ងៃនេះ ដោយ ឯកឧត្តម គូម៉ាម៉ារ៉ូ យូជិ ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និងលោកស្រី អ៊ូរ៉ាតា ហ្វ៊ូគីមិ អ្នកសម្របសម្រួលគម្រោងរបស់អង្គការASACនៅស្ថានទូតជប៉ុន។



ក្មេងៗកំពុងអានសៀវភៅជាមួយគ្នា

ក្នុងគម្រោងនេះ អង្គការ ASAC នឹងសាងសង់អគារសិក្សា ២ខ្នង ដោយមានបំពាក់បរិក្ខារអនាម័យ និងបណ្ណាល័យសហគមន៍ ព្រម ទាំងបំពាក់សង្ហារឹមក្នុងអនុវិទ្យាល័យទួលផ្ទឹក និងជួសជុលអគារសិក្សា១ខ្នងក្នុង សាលាបឋមសិក្សាអម្ពវន្តឃោធារ៉ាម ក្នុង ស្រុកជុំគីរី ខេត្ត កំពត។ យើងសង្ឃឹមថា គម្រោងនេះនឹងផ្តល់បរិស្ថានអប់រំដែលមានសុវត្ថិភាពនិងផាសុខភាពដល់សិស្សអនុវិទ្យាល័យជាង២៦០នាក់ និងសិស្សបឋមសិក្សាជាង៣៨០នាក់ដែលបច្ចុប្បន្នកំពុងសិក្សាក្នុងអគារសិក្សាដែលចាស់ទ្រុឌទ្រោម។ ជាងនេះទៅទៀត ដើម្បីឲ្យការគាំទ្រនេះទទួលបាននូវប្រសិទ្ធភាពនោះ ASACនឹងផ្តល់វគ្គបណ្តុះបណ្តាលអំពីកម្មវិធីពង្រឹងសមត្ថភាពដល់គណៈគ្រប់គ្រងសាលា និងប្រជាជនក្នុងសហគមន៍។

កម្មវិធីជំនួយឥតសំណងសម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុនបានចាប់ផ្តើមនៅប្រទេសកម្ពុជាតាំងពីឆ្នាំ ២០០២ ដើម្បីគាំទ្រដល់សកម្មភាពរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីជួយដល់ការអភិវឌ្ឍន៍ និងស្តាបនាប្រទេសកម្ពុជាឡើងវិញនៅតាមកំរិតមូលដ្ឋាន។ ចាប់តាំងពីឆ្នាំ២០០២មក រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកាជាង២០.៦លានដុល្លាអាមេរិកដល់គម្រោងចំនួន ៧៨ គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុនដែលផ្តោតសំខាន់ទៅលើវិស័យអប់រំនៅកម្រិតមូលដ្ឋាន វិស័យសុខាភិបាល វិស័យកសិកម្ម និងសកម្មភាពបោសសំអាតមីន។ គម្រោង នេះគឺជាគម្រោងទី៨តាមរយៈគ្រោងការណ៍នៃជំនួយនេះសម្រាប់ឆ្នាំសារពើពន្ធឆ្នាំ២០១៣របស់ជប៉ុន(មេសា២០១៣ដល់មិនា២០១៤)។



ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៩-៣៣០
អ៊ីមែល: eco.jpn@.pp.mofa.go.jp
គេហទំព័រ: http://www.kh.emb-japan.go.jp